វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ក្រុមប្រឹក្សារដ្ឋ/រដ្ឋសភា

ក្រឹត្យ/ច្បាប់/០៩ ក្រ/០៨ កុម្ភៈ ១៩៩៣/

ស្តីពី ការបែងចែកទ្រព្យសម្បត្តិ

មាត្រា១:

ទ្រព្យសម្បត្តិ ជាចលនវត្ថុ និង ជាអចលនវត្ថុទាំងអស់ដែលគណបក្សប្រជាជនកម្ពុជា និង រដ្ឋកម្ពុជាបានប្រើប្រាស់ និង គ្រប់គ្រងពីឆ្នាំ១៩៧៩ មកដល់បច្ចុប្បន្ន ត្រូវបែងចែកគ្នា ចាប់ពីច្បាប់នេះ ចូលជាធរមាន។

មាត្រា២:

ទ្រព្យសម្បត្តិជាចលនវត្ថុ និងជាអចលនវត្ថុទាំងអស់ ដែលរដ្ឋាភិបាលនៃរដ្ឋកម្ពុជា បានប្រើប្រាស់ និងគ្រប់គ្រងរហូតមកដល់បច្ចុប្បន្ន ត្រូវចាត់ទុកជាទ្រព្យសម្បត្តិរបស់រដ្ឋ

មាត្រា៣:

ទ្រព្យសម្បត្តិជាចលនវត្ថុ និងអចលនវត្ថុទាំងអស់ ដែលគណបក្សប្រជាជនកម្ពុជា បានប្រើប្រាស់ និង គ្រប់គ្រងរហូតមកដល់បច្ចុប្បន្ន ត្រូវចាត់ទុកជា ទ្រព្យសម្បត្តិរបស់គណបក្សប្រជាជន កម្ពុជា ។

មាត្រា៤:

ទ្រព្យសម្បត្តិជាចលនវត្ថុ និង អចលនវត្ថុដែលបច្ចុប្បន្ន នៅប្រើប្រាស់ និង គ្រប់គ្រងរួមគ្នា ត្រូវរដ្ឋាភិបាលនៃរដ្ឋកម្ពុជា និងគណបក្សប្រជាជនកម្ពុជាពិភាក្សាបែងចែក ដោយឯកភាពគ្នា និងតាមស្ថានការជាក់ស្តែង ។

មាត្រា៥:

រដ្ឋាភិបាលនៃរដ្ឋកម្ពុជា និងគណបក្សប្រជាជនកម្ពុជា ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិខាងលើនេះរៀង១ ខ្លួន ចាប់តាំងពីច្បាប់នេះចូលជាធរមាន ។

មាត្រា៦:

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។